ព្រះរាជាណាចក្រកម្ពុជា

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំសាធារណរដ្ឋកូរ៉េ

លេខ: ៣៣៦.០៩ សកស

# ជាតិ សាសនា ព្រះមហាក្សត្រ

សេអ៊ូល, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** ការតាំងពិព័រណ៍ G-Trade GBC នៅខេត្តខ្យុងហ្គី ( Gyeonggi)

**យោង:** លិខិតជូនដំណឹង របស់មជ្ឈមណ្ឌលពាណិជ្ជកម្ម ខ្នាតតូច-មធ្យម ខេត្តខ្យុងហ្គី " ជូនភ្ជាប់ "

ខ្ញុំបាទមានកិត្តិយស សូមជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា មជ្ឈមណ្ឌលពាណិជ្ជកម្ម ខ្នាតតូច-មធ្យម ខេត្តខ្យុងហ្គី Gyeonggi Small & Medium Business Center បានជូនពត៌មានអំពីការតាំងពិព័រណ៍ G-Trade GBC ដែលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០៩ នៅទីក្រុងស៊ូវ៉ុន ខេត្តខ្យុងហ្គី សាធារណរដ្ឋកូរ៉េ ។

មជ្ឈមណ្ឌលពាណិជ្ជកម្ម ខ្នាតតូច-មធ្យម ខេត្តខ្យុងហ្គី បានអញ្ជើញ តំណាងមកពីប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងទៀត ចូលរួមការតាំងពិព័រណ៍ ដែលពាក់ព័ន្ធជាមួយការធ្វើអាជីវកម្មលើមុខទំនិញ Auto Parts, Iron & Steel Parts, Textile Parts, Display Parts, Wireless IT, Semi conductor ។

ពត៌មានពិស្តារ ទាក់ទិនការតាំងពិព័រណ៍ មានក្នុងឯកសារជូនភ្ជាប់ សូមទាក់ទង:

Contact Point:

Mr. Michael Hwoang

Tel: +82-2-999-1548

Fax: +82-2-999-4096

E-mail: jsgkorea94@naver.com; jsgkorea94@yahoo.com.kr

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបនិងពិនិត្យសម្រេច ដ៏ខ្ពង់ខ្ពស់ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរព ដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ ។

**ចម្លងជូន :**

-ក្រសួងពាណិជ្ជកម្ម

" ដើម្បីជូនជ្រាបនិងសហការ "

-ឯកសារ-កាលប្បវត្តិ

**ឯកអគ្គរាជទូត**

**លឹម សំកុល**